# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៦៣

## ស្តីពី

## ការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

## ត្រាស់បង្គាប់

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**_

ត្រូវបានបង្កើត "គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ" ដែលសរសេរជាអក្សរកាត់ថា "**គ.ជ.ន.ជ.**"។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា ២.**

**គ.ជ.ន.ជ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងផែនការ | | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ០១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| - មន្ត្រីជាន់ខ្ពស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | ជាអគ្គលេខាធិការ។ |

ក្រៅពីសមាជិកខាងលើនេះ **គ.ជ.ន.ជ.** អាចស្នើឲ្យតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកចំពោះកិច្ចតាមការចាំបាច់។

សមាសភាពនៃ **គ.ជ.ន.ជ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៣._**

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានមួយជាសេនាធិការជូន **គ.ជ.ន.ជ.** សម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយដែលមានទីស្នាក់ការនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ៤._**

នៅថ្នាក់ក្រោមជាតិមានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ន.ជ.

**មាត្រា ៥._**

**គ.ជ.ន.ជ.** មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- ផ្តួចផ្តើម រៀបចំ និងសម្របសម្រួលផែនការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិនៅព្រះរាជាណាចក្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌
- ដឹកនាំ ពិគ្រោះយោបល់ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី
- ណែនាំនិងសម្របសម្រួល ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីថ្នាក់រាជធានី និងក្នុងការរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- គាំទ្របច្ចេកទេស ក្នុងការរៀបចំគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម
- ពិនិត្យនិងសម្រេចលើប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- ពិនិត្យនិងលើកសំណើ ដើម្បីសុំការយល់ព្រមពីរាជរដ្ឋាភិបាលចំពោះផែនការរៀបចំដែនដីថ្នាក់ជាតិនិងថ្នាក់តំបន់។ ផែនការរៀបចំដែនដីថ្នាក់ជាតិនិងថ្នាក់តំបន់ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។
- ពិនិត្យផ្តល់យោបល់និងលើកសំណើដើម្បីសុំការសម្រេចពីរាជរដ្ឋាភិបាល ចំពោះផែនការរៀបចំដែនដីថ្នាក់ខេត្តនិងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- តាមដានការអនុវត្តផែនការរៀបចំដែនដីថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ និងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- ពិនិត្យនិងសម្រេចថវិកាប្រចាំឆ្នាំរបស់ **គ.ជ.ន.ជ.**
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ន.ជ.

**មាត្រា ៦.**_

**គ.ជ.ន.ជ.** ត្រូវប្រជុំ២ដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ **គ.ជ.ន.ជ.** អាចធ្វើការប្រជុំវិសាមញ្ញបានតាមការចាំបាច់។ ក្នុងករណីចាំបាច់ ប្រធាន **គ.ជ.ន.ជ.** អាចអញ្ជើញប្រធានតំណាងក្រសួង ស្ថាប័ន អង្គភាព មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំ ពិគ្រោះពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបអាចដឹកនាំការប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន។

**គ.ជ.ន.ជ.** ត្រូវរៀបចំនិងអនុម័តនូវរបៀបរបបការងារនិងបទបញ្ជាផ្ទៃក្នុងនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន។

**មាត្រា ៧.**_

សមាជិកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីពុំអាចចូលរួមប្រជុំបាន សមាជិកនោះអាចស្នើទៅប្រធានស្ថាប័នរបស់ខ្លួនឲ្យចាត់តាំងតំណាងមួយរូប ដើម្បីជំនួសខ្លួនក្នុងការចូលរួមប្រជុំដោយធ្វើប្រតិភូកម្មអំណាចឲ្យតំណាងរូបនោះមានសិទ្ធិសម្រេចបាន។

**មាត្រា ៨.**_

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប អមដោយអគ្គលេខាធិការរងមួយចំនួនដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យនិង/ឬអនុក្រឹត្យតាមសំណើរបស់ប្រធាន**គ.ជ.ន.ជ.**។

**មាត្រា ៩.**_

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន**គ.ជ.ន.ជ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១០.**_

**គ.ជ.ន.ជ.** ប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ១១.**_

**គ.ជ.ន.ជ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១២.**_

**គ.ជ.ន.ជ.** មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាដោយឡែកដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

គ.៥.១.៥. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.**_

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០១១២.០៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ:៤៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១២

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា